**រាជរដ្ឋាភិបាលកម្ពុជា**

**គណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ**

# ការអនុវត្តមុខងាររបស់
# គណៈកម្មាធិការទទួលបន្ទុក
# កិច្ចការនារី និងកុមារឃុំ សង្កាត់

# មាតិកា

អារម្ភកថា ០១

១. គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំសង្កាត់ ០២

១.១. សមាសភាពរបស់គណៈកម្មាធិការ ០២

១.២. តួនាទី និងភារកិច្ចរបស់គណៈកម្មាធិការ ០៣

១.៣. តួនាទី និងភារកិច្ចរបស់សមាជិកនីមួយៗ ០៥

២. ការផ្តល់មូលនិធិគាំទ្រ ១១

២.១. គោលបំណងនៃការផ្តល់មូលនិធិ ១១

២.២. លក្ខខណ្ឌនៃការផ្តល់មូលនិធិ ១២

២.៣. សូចនាករ ១២

២.៤. នីតិវិធីហិរញ្ញវត្ថុ ១៣

៣. ការអនុវត្តមុខងារ ១៥

៣.១. ការប្រជុំរបស់គណៈកម្មាធិការ ១៥

៣.២. ទម្រង់របាយការណ៍ និងកំណត់ហេតុ ២២

៤. យន្តការគាំទ្រ ៣៤

៤.១. អង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត ក្រុង ៣៤

៤.២. មន្ទីរជំនាញនានាក្នុងខេត្ត ក្រុង ៣៥

៤.៣. សាលាស្រុក ខណ្ឌ ៣៦

library.ncdd.gov.kh
014388

# អារម្ភកថា

គណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការរៀបរៀងសៀវភៅនេះឡើង ក្នុងគោលបំណងដើម្បីជួយដល់គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់អនុវត្តមុខងារ និងតួនាទីរបស់ខ្លួនឱ្យបានល្អប្រសើរ និងឆ្លើយតបទៅនឹងសូចនាករដែលបានកំណត់។

សៀវភៅនេះបរិយាយអំពី ÷

- ការបង្កើតគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំសង្កាត់
- ការផ្តល់មូលនិធិគាំទ្រ
- ការអនុវត្តមុខងារ និងតួនាទីរបស់គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ និង
- យន្តការគាំទ្រ។

គណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ នឹងទទួលស្វាគមន៍ជានិច្ចនូវមតិរិះគន់ស្ថាបនា ដើម្បីកែលម្អសៀវភៅនេះ។

# ១. គណៈកម្មាធិការទទួលបន្ទុក កិច្ចការនារី និងកុមារឃុំ សង្កាត់

ឃុំចំនួន៤២២ នៃខេត្តចំនួន៦ ដែលជាឃុំគោលដៅរបស់អង្គការយូនីសេហ្វ បានបង្កើតគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ តាំងពីឆ្នាំ២០០៤ តាមរយៈកម្មវិធីសិទ្ធិកុមារ ។

ផ្អែកលើបទពិសោធន៍នៃការអនុវត្តសាកល្បងកន្លងមក គ.ជ.វ.វ បានចេញសេចក្តីណែនាំ លេខ ០៨២ ស.ណ.ន/គ.ជ.វ.វ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០០៧ ស្តីពីការរៀបចំ និងបង្កើតគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារនៅគ្រប់ឃុំ សង្កាត់ទូទាំងប្រទេស ដើម្បីឱ្យឃុំ សង្កាត់ទាំងអស់នៅទូទាំងប្រទេសរៀបចំ និងបង្កើតគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ ។

## ១.១. សមាសភាពគណៈកម្មាធិការ

គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ ត្រូវមានសមាសភាព ដូចខាងក្រោម ÷

- មេឃុំ ចៅសង្កាត់ ជាប្រធាន
- ជំទប់ទី២ ចៅសង្កាត់រងទី២ ជាអនុប្រធាន
- អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ ជាសមាជិកអចិន្ត្រៃយ៍
- ស្មៀនឃុំ សង្កាត់ ជាសមាជិក

- នាយ ឬនាយរងប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់១រូប ជាសមាជិក
- នាយកសាលា ឬតំណាង១រូប ជាសមាជិក
- ប្រធានមណ្ឌលសុខភាព ឬតំណាង១រូប ជាសមាជិក
- មេភូមិ ឬអនុប្រធានភូមិ១រូប គ្រប់ភូមិ ជាសមាជិក

សមាជិកគណៈកម្មាធិការនេះ អាចមានការប្រែប្រួលដោយយោងទៅតាមចំនួនភូមិក្នុងឃុំ សង្កាត់នីមួយៗ។

ដើម្បីលើកកម្ពស់ដល់ការចូលរួមរបស់ស្ត្រី គណៈកម្មាធិការនេះត្រូវមានសមាជិកជានារីយ៉ាងតិច៤០% នៃសមាជិកទាំងអស់។

ករណីមេឃុំ ចៅសង្កាត់ ឬជំទប់ទី២ ចៅសង្កាត់រងទី២ ជានារី និងជាអ្នកទទួលបន្ទុកកិច្ចការនារីនិងកុមារឃុំ សង្កាត់ ត្រូវជ្រើសរើសសមាជិកម្នាក់ក្នុងចំណោមសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលមានសមត្ថភាព ធ្វើជាសមាជិកអចិន្ត្រៃយ៍នៃគណៈកម្មាធិការ។

## ១.២. តួនាទី និងភារកិច្ចរបស់គណៈកម្មាធិការ

គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់មានតួនាទីនិងភារកិច្ចដូចខាងក្រោម ÷

- រៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់គណៈកម្មាធិការ ដាក់ជូនក្រុមប្រឹក្សាឃុំ សង្កាត់អនុម័ត។

- ផ្តល់ប្រឹក្សាយោបល់ និងជួយក្រុមប្រឹក្សាឃុំ សង្កាត់ និងមេឃុំ ចៅសង្កាត់ ចំពោះការងារពាក់ព័ន្ធកិច្ចការនារី និងកុមារនៅឃុំ សង្កាត់ ។
- អប់រំផ្សព្វផ្សាយដល់ប្រជាពលរដ្ឋឱ្យយល់ដឹងអំពីច្បាប់ គោលនយោបាយនានារបស់រដ្ឋពាក់ព័ន្ធសិទ្ធិនារី និងកុមារនៅឃុំសង្កាត់ និងបំផុសចលនាសហគមន៍លើវិស័យសុខភាព អប់រំ កិច្ចការពារ និងការអភិវឌ្ឍកុមារ ព្រមទាំងការចុះបញ្ជីអត្រានុកូលដ្ឋានជូនទារក និងកុមារ ។
- ទាក់ទាញការគាំទ្រ ដើម្បីឱ្យនារីបានចូលរួមធ្វើសេចក្តីសម្រេចលើការអភិវឌ្ឍនៅមូលដ្ឋានឃុំ សង្កាត់ ។
- បង្កើន និងពង្រឹងនូវការប្រាស្រ័យទាក់ទងកិច្ចសហការ និងការសម្របសម្រួលរវាងក្រុមប្រឹក្សាឃុំ សង្កាត់ និងអ្នកផ្តល់សេវាកម្ម និងអ្នកភូមិដែលធ្វើសកម្មភាពជួយនារី និងកុមារនៅក្នុងឃុំ សង្កាត់របស់ខ្លួន ។
- ជួយក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងការប្រមូលវិភាគព័ត៌មាន ទិន្នន័យពាក់ព័ន្ធនឹងបញ្ហា និងតម្រូវការរបស់នារី និងកុមារដើម្បីដាក់បញ្ចូលក្នុងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ និងកម្មវិធីវិនិយោគឃុំ សង្កាត់ ។
- ចូលរួមអនុវត្ត ពិនិត្យ តាមដាន និងវាយតម្លៃផែនការសកម្មភាពឃុំ សង្កាត់ពាក់ព័ន្ធស្ថានភាពនារី និងកុមារ ។
- តាមដានស្ថានភាពនារី និងកុមារក្នុងឃុំ សង្កាត់ និងធ្វើរបាយការណ៍ទៀងទាត់ជូនក្រុមប្រឹក្សាឃុំ សង្កាត់ ព្រមទាំងដាក់បញ្ចូលក្នុងរបាយការណ៍ឃុំ សង្កាត់ ។

មេឃុំ ចៅសង្កាត់ដែលជាប្រធានគណៈកម្មាធិការ ត្រូវមានការទទួលខុសត្រូវចំពោះក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន។ គណៈកម្មាធិការត្រូវសម្របសម្រួល និងសហការយ៉ាងជិតស្និទ្ធជាមួយអ្នកផ្តល់សេវាកម្មផ្នែកសង្គមនានា អ្នកស្ម័គ្រចិត្តភូមិ និងសហគមន៍នៅក្នុងឃុំ សង្កាត់ ដើម្បីបំពេញតួនាទីភារកិច្ចខាងលើឱ្យមានប្រសិទ្ធភាព។

## ១.៣. តួនាទី និងភារកិច្ចរបស់សមាជិកនីមួយៗ

### ១.៣.១. ប្រធានគណៈកម្មាធិការ

ប្រធានគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារមានតួនាទី និងភារកិច្ចដូចខាងក្រោម ÷

- ទទួលខុសត្រូវលើការងាររួមរបស់គណៈកម្មាធិការ ករណីប្រធានគណៈកម្មាធិការអវត្តមាន ត្រូវផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរទៅអនុប្រធានជាអ្នកទទួលខុសត្រូវជំនួស។ បើអនុប្រធានអវត្តមានត្រូវផ្ទេរភារកិច្ចបន្ត ទៅឱ្យសមាជិកអចិន្ត្រៃយ៍ជាអ្នកដឹកនាំការងារជំនួស។
- ជាអធិបតីរាល់កិច្ចប្រជុំរបស់គណៈកម្មាធិការ។
- អញ្ជើញសមាជិកគណៈកម្មាធិការ ចូលរួមក្នុងគ្រប់កិច្ចប្រជុំទៀងទាត់របស់គណៈកម្មាធិការ។
- ដឹកនាំ និងចូលរួមជាមួយសមាជិកគណៈកម្មាធិការដើម្បីអនុវត្តសកម្មភាពនានារបស់គណៈកម្មាធិការនៅតាមភូមិនានា។

- កៀរគរធនធានពីប្រភពនានា ដើម្បីរៀបចំគម្រោងនានាឆ្លើយតបទៅនឹងតម្រូវការរបស់នារី និងកុមារដែលបានលើកឡើងក្នុងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ និងកម្មវិធីវិនិយោគឃុំ សង្កាត់ ។
- ធានាឱ្យមានផែនការសកម្មភាពនិងថវិការបស់គណៈកម្មាធិការ និងដាក់បញ្ចូលផែនការសកម្មភាព និងថវិកានោះទៅក្នុងផែនការសកម្មភាព និងថវិការបស់ឃុំ សង្កាត់ ។
- ទាក់ទាញការគាំទ្រ និងជំរុញក្រុមប្រឹក្សាឃុំ សង្កាត់ឱ្យវិភាជន៍ថវិកាវិនិយោគឃុំ សង្កាត់ សម្រាប់គាំទ្រគម្រោងសេវាកម្មសង្គមនៅក្នុងឃុំ សង្កាត់របស់ខ្លួន ។
- ចលនាប្រជាពលរដ្ឋនៅក្នុងមូលដ្ឋាន ឱ្យចុះបញ្ជីអត្រានុកូលដ្ឋានពិសេសការចុះសៀវភៅអត្រានុកូលដ្ឋានកំណើត ពេលមានទារកកើតឱ្យបានទាន់ពេលវេលាកំណត់ ។
- គាំទ្រនូវគំនិតផ្តួចផ្តើមនានារបស់សមាជិកគណៈកម្មាធិការ និងលើកទឹកចិត្តដល់សមាជិកគណៈកម្មាធិការ ដែលមានស្នាដៃឆ្នើមក្នុងការបំពេញការងារពាក់ព័ន្ធនារី និងកុមារ ។
- ធានាឱ្យមានរបាយការណ៍ទៀងទាត់ ស្តីពីការងាររបស់គណៈកម្មាធិការជូនក្រុមប្រឹក្សាឃុំ សង្កាត់ ព្រមទាំងការដាក់បញ្ចូលនូវរបាយការណ៍របស់គណៈកម្មាធិការនេះទៅក្នុងរបាយការណ៍ឃុំ សង្កាត់ផងដែរ ។

### ១.៣.២. អនុប្រធានគណៈកម្មាធិការ

អនុប្រធានគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារមាន តួនាទី និងភារកិច្ចដូចខាងក្រោម ÷

- ជំនួសប្រធាន នៅពេលប្រធានអវត្តមាន ។
- ចូលរួមកិច្ចប្រជុំរបស់គណៈកម្មាធិការ ។
- សហការ និងគាំទ្រដល់សមាជិកអចិន្ត្រៃយ៍ ដើម្បីអនុវត្តការងារក្នុងគោលដៅធានានូវប្រសិទ្ធភាពការងាររបស់គណៈកម្មាធិការ ។
- បំពេញតួនាទីភារកិច្ចបន្ថែមតាមការប្រគល់ឱ្យពីប្រធានគណៈកម្មាធិការ ។

### ១.៣.៣. សមាជិកអចិន្ត្រៃយ៍គណៈកម្មាធិការ

សមាជិកអចិន្ត្រៃយ៍របស់គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារមានតួនាទី និងភារកិច្ចដូចខាងក្រោម ÷

- រៀបចំសេចក្តីព្រាងផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់គណៈកម្មាធិការ ។
- ពិនិត្យ តាមដានការអនុវត្តការងារ និងរៀបចំរបាយការណ៍សកម្មភាពរបស់គណៈកម្មាធិការ ។
- រៀបចំ និងជួយចាត់ចែងការប្រជុំប្រចាំខែ ឆមាស និងប្រចាំឆ្នាំរបស់គណៈកម្មាធិការ ។

- សហការ និងសម្របសម្រួលជាមួយសមាជិកគណៈកម្មការនានា ដើម្បីធានានូវការអនុវត្តសកម្មភាពរបស់គណៈកម្មាធិការឱ្យទទួលបានជោគជ័យ ។
- ចូលរួមប្រមូលព័ត៌មាន ទិន្នន័យពាក់ព័ន្ធស្ថានភាពនារី និងកុមារ និងធ្វើការវិភាគព័ត៌មាន ទិន្នន័យពីស្ថានភាពនារី និងកុមារក្នុងឃុំ សង្កាត់របស់ខ្លួនព្រមទាំងឯកសារស្ថានភាពឃុំ សង្កាត់ផងដែរ ។
- សម្របសម្រួល និងស្នើបញ្ចូលតម្រូវការដែលពាក់ព័ន្ធស្ថានភាពនារី និងកុមារទៅក្នុងផែនការអភិវឌ្ឍន៍ឃុំសង្កាត់ និងកម្មវិធីវិនិយោគឃុំ សង្កាត់ ។
- ពិនិត្យ តាមដាន និងវាយតម្លៃការងារអប់រំកុមារតូចៗ ជាអាទិ៍ ការងារមត្តេយ្យសហគមន៍ និងការអប់រំឪពុកម្តាយ ។
- សហការជាមួយសមាជិកគណៈកម្មាធិការនានា ជាពិសេសមេភូមិ និង/ឬអនុប្រធានភូមិ ដើម្បីកៀរគរឱ្យមានការចូលរួមពីអ្នកភូមិ ពិសេសនារី និងយុវជន យុវនារី នៅក្នុងការអភិវឌ្ឍមូលដ្ឋានឃុំ សង្កាត់ និងអភិបាលកិច្ចមូលដ្ឋាន ។
- សហការ និងជួយស្មៀនឃុំ សង្កាត់ ដើម្បីរៀបចំផែនការ និងរបាយការណ៍ចំណាយថវិការបស់គណៈកម្មាធិការ ។ ការបំពេញតួនាទី និងភារកិច្ចរបស់សមាជិកអចិន្ត្រៃយ៍ នឹងជួយបំពេញបន្ថែមទៅលើការបំពេញតួនាទី និងភារកិច្ចរបស់អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ ។

### ១.៣.៤. សមាជិកគណៈកម្មាធិការនានា

សមាជិកគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារមានតួនាទី និងភារកិច្ចដូចខាងក្រោម ÷

- ចូលរួមពិនិត្យ ពិភាក្សា និងអនុម័តលើសេចក្តីព្រាងផែនការសកម្មភាព និងផែនកាថវិការបស់គណៈកម្មាធិការ និងអនុវត្តផែនការសកម្មភាពប្រចាំឆ្នាំ ព្រមទាំងធ្វើសេចក្តីរាយការណ៍ស្តីពីការអនុវត្តការងារតាមវិស័យរបស់ខ្លួន។
- ចូលរួមប្រមូលព័ត៌មាន ទិន្នន័យពាក់ព័ន្ធស្ថានភាពនារី និងកុមារ និងធ្វើការវិភាគព័ត៌មាន ទិន្នន័យពីស្ថានភាពនារី និងកុមារក្នុងឃុំ សង្កាត់របស់ខ្លួន ព្រមទាំងឯកសារស្ថានភាពឃុំ សង្កាត់ផងដែរ។
- យកចិត្តទុកដាក់ទប់ស្កាត់ និងអន្តរាគមន៍ចំពោះករណីអំពើហិង្សាក្នុងគ្រួសារ ការរំលោភបំពាន ការជួញដូរផ្លូវភេទ ការកេងប្រវ័ញ្ចពលកម្មនារី និងកុមារនៅក្នុងឃុំ សង្កាត់។
- ចូលរួមកិច្ចប្រជុំនានារបស់គណៈកម្មាធិការ និងផ្តល់ព័ត៌មានទាក់ទងនឹងកិច្ចការពារកុមារ ការងារអប់រំ និងសុខភាពពាក់ព័ន្ធស្ថានភាពនារី និងកុមារជូនគណៈកម្មាធិការជាទៀងទាត់។
- បំផុស និងលើកទឹកចិត្តប្រជាពលរដ្ឋឱ្យចូលរួមក្នុងសកម្មភាពនានាដើម្បីជួយនារី និងកុមារនៅក្នុងមូលដ្ឋានភូមិ ឃុំ សង្កាត់របស់ខ្លួន។

☞ មេភូមិ ឬអនុប្រធានភូមិដែលជាសមាជិកគណៈកម្មាធិការទទួលបន្ទុកបន្ថែមលើតួនាទី និងភារកិច្ចខាងលើ ដូចខាងក្រោម ÷

- ចូលរួមផ្តល់យោបល់ជូនគណៈកម្មាធិការអំពីបញ្ហាប្រឈម ដែលពាក់ព័ន្ធនឹងស្ថានភាពនារី និងកុមារនៅក្នុងភូមិរបស់ខ្លួន ។
- ធានាផ្តល់ព័ត៌មាននានាដែលពាក់ព័ន្ធនឹងភូមិរបស់ខ្លួនជូនប្រជាពលរដ្ឋតាមការណែនាំរបស់គណៈកម្មាធិការ និងក្រុមប្រឹក្សាឃុំ សង្កាត់ ។
- ពិនិត្យ តាមដានស្ថានភាពនារី និងកុមារនៅក្នុងភូមិ និងរាយការណ៍ជាទៀងទាត់ជូនគណៈកម្មាធិការ ។

☞ ស្មៀនឃុំ សង្កាត់បន្ថែមលើតួនាទី និងភារកិច្ចខាងលើ មានភារកិច្ចជួយប្រធានគណៈកម្មាធិការ ដើម្បីរៀបចំផែនការ និងរបាយការណ៍ហិរញ្ញវត្ថុរបស់គណៈកម្មាធិការ ព្រមទាំងបញ្ចូលរបាយការណ៍សកម្មភាពរបស់គណៈកម្មាធិការទៅក្នុងរបាយការណ៍ឃុំ សង្កាត់ ។

# ២. ការផ្ដល់មូលនិធិគាំទ្រ

## ២.១. គោលបំណងនៃការផ្ដល់មូលនិធិ

ក្នុងទិសដៅជំរុញឱ្យគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់អនុវត្តមុខងាររបស់ខ្លួន ឱ្យបានល្អប្រសើរស្របតាមសេចក្ដីណែនាំ ក្រុមគាំទ្រកម្មវិធីនៃ គ.ជ.វ.វ និងគម្រោងគាំទ្រការអភិវឌ្ឍបែបប្រជាធិបតេយ្យតាមរយៈវិមជ្ឈការ និងវិសហមជ្ឈការ បានផ្ដួចផ្ដើមរកមូលនិធិបន្ថែមសម្រាប់គាំទ្រដល់ការអនុវត្តមុខងាររបស់គណៈកម្មាធិការ នៅក្នុងឃុំ សង្កាត់ចំនួន ១.១៩៩ ដែលមិនស្ថិតនៅក្នុងខេត្ត ក្រុងគោលដៅរបស់អង្គការយូនីសេហ្វ។

គោលបំណងនៃការផ្ដល់មូលនិធិគាំទ្រគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ គឺដើម្បី ÷

- ធានាថាស្ត្រីមានផ្ទៃពោះបានទទួលការពិនិត្យផ្ទៃពោះ
- ធានាថាស្ត្រីមានផ្ទៃពោះបានសម្រាលកូនដោយឆ្មបជំនាញនៅកន្លែងផ្ដល់សេវាសុខាភិបាល ( មណ្ឌលសុខភាព សម្ភព មន្ទីរពេទ្យ)
- កាត់បន្ថយអត្រាមរណៈរបស់ស្ត្រីមានផ្ទៃពោះ ក្នុងពេលមានផ្ទៃពោះ ពេលសម្រាល និងក្រោយសម្រាល
- ធានាថាកុមារអាយុក្រោម១ឆ្នាំទទួលបានការចាក់ថ្នាំបង្ការជំងឺកញ្ជ្រិល
- កាត់បន្ថយអត្រាមរណៈរបស់កុមារអាយុក្រោម៥ឆ្នាំ
- ធានាថាទារកទើបកើតបានទទួលសំបុត្រកំណើតក្នុងរយៈពេល៣០ថ្ងៃ

- ធានាថាកុមារអាយុ៦-១១ឆ្នាំបានចុះឈ្មោះចូលរៀននៅសាលាបឋមសិក្សា
- កាត់បន្ថយអត្រាកុមារអាយុ៦-១១ឆ្នាំអវត្តមានពីសាលារៀនលើសពី១៥ថ្ងៃជាប់ៗគ្នា
- ដោះស្រាយបញ្ហាពាក់ព័ន្ធសន្តិសុខ និងសណ្តាប់ធ្នាប់ដែលប៉ះពាល់ដល់នារី និងកុមារក្នុងឃុំ សង្កាត់ ។

## ២.២. លក្ខខណ្ឌនៃការផ្តល់មូលនិធិ

ដើម្បីទទួលបានមូលនិធិគាំទ្រគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំសង្កាត់ ឃុំសង្កាត់នីមួយៗត្រូវបំពេញតាមល័ក្ខខ័ណ្ឌដូចខាងក្រោម ÷

- បង្កើតគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់
- មានឆន្ទៈក្នុងការសម្រេចឱ្យបាននូវគោលបំណងនៃការផ្តល់មូលនិធិ
- មានឆន្ទៈក្នុងការផ្តល់របាយការណ៍រីកចម្រើនឱ្យបានទៀតទាត់ ដែលរបាយការណ៍នោះត្រូវឆ្លើយតបទៅនឹងសូចនាករដែលបានកំណត់ ។

## ២.៣. សូចនាករ

សូចនាករសម្រាប់វាស់វែងលើប្រសិទ្ធភាពនៃការផ្តល់មូលនិធិគាំទ្រដល់គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារីនិងកុមារឃុំសង្កាត់ មានដូចខាងក្រោម ÷

- ស្ត្រីមានផ្ទៃពោះ......%បានទទួលការផ្ទៃពោះ
- ស្ត្រីមានផ្ទៃពោះ......%បានសម្រាលកូនដោយពេទ្យឆ្មបនៅកន្លែងផ្តល់សេវាសុខាភិបាល ( មណ្ឌល សុខភាព ឬមន្ទីរពេទ្យ ឬសម្ភព)

- កុមារអាយុក្រោម១ឆ្នាំ......%បានទទួលថ្នាំបង្ការជំងឺកញ្ជ្រិល
- ទារកទើបកើត......%បានទទួលសំបុត្រកំណើតក្នុងរយៈពេល៣០ថ្ងៃ
- កុមារអាយុ៦-១១ឆ្នាំ ..........% បានចុះឈ្មោះចូលរៀននៅសាលាបឋមសិក្សា
- កុមារអាយុ៦-១១ឆ្នាំ.........%អវត្តមានពីសាលារៀនលើសពី១៥ថ្ងៃជាប់ៗគ្នា។

**បញ្ជាក់ :** គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ត្រូវកំណត់ចំនួនភាគរយនៃសូចនាករនីមួយៗ ដែលខ្លួនគិតថាអាចសម្រេចបាន នៅដំណាច់ឆ្នាំនីមួយៗ ដោយផ្អែកតាមស្ថានភាពជាក់ស្តែងនៃឃុំ សង្កាត់របស់ខ្លួន។

## ២.៤. នីតិវិធីហិរញ្ញវត្ថុ

ឃុំ សង្កាត់នីមួយៗទទួលបានថវិកាចំនួន២០០ដុល្លារស្មើៗគ្នាក្នុង១ឆ្នាំ សម្រាប់គណៈកម្មាធិការអនុវត្តតួនាទី និងភារកិច្ចរបស់ខ្លួន។ ថវិកានេះបញ្ចូលទៅក្នុងថវិកាឃុំ សង្កាត់ត្រង់លេខកូដ **៧៤.០២.២០ "ការចូលរួមធនធានពីអង្គការ និងសមាគមអន្តរជាតិផ្សេងៗ"**។ ថវិកានេះសម្រាប់ឱ្យគណៈកម្មាធិការចំណាយទៅលើ ÷

- ចំណាយលើអាហារសម្រន់ និងការថតចម្លងឯកសារសម្រាប់ការប្រជុំរបស់គណៈកម្មាធិការ

- ចំណាយសម្រាប់ថ្លៃធ្វើដំណើររបស់សមាជិកគណៈកម្មាធិការចូលរួមប្រជុំប្រចាំខែនៅសាលាឃុំ សង្កាត់ និងប្រជុំត្រីមាសនៅសាលាស្រុក ខណ្ឌ
- ចំណាយសម្រាប់សម្ភារៈការិយាល័យ ។

| កូដថវិកា | ប្រភេទចំណាយ | ឯកតា | ចំនួន | តម្លៃ/ឯកតា | សរុប ($) |
|---|---|---|---|---|---|
| ៦១.០៧ | រៀបចំប្រជុំទៀងទាត់ | ប្រជុំ | 12 | 4 | 48 |
| ៦១.០៦ | សម្ភារៈការិយាល័យ | ខែ | 12 | 4 | 48 |
| ៦១.០៤ | ថ្លៃធ្វើដំណើរ | រូម | 1 | 104 | 104 |
| សរុបរួម | | | | | 200 |

នីតិវិធីនៃការចំណាយថវិកាចំនួន២០០ដុល្លារនេះ នឹងចំណាយតាមរយៈបេឡាបុរេប្រទាន ដោយអនុវត្តតាមនីតិវិធី ដែលមានចែងនៅក្នុងសៀវភៅណែនាំស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ សង្កាត់ ។

**បញ្ជាក់ :** ថវិកាដែលសល់ពីការចំណាយនៃឆ្នាំនីមួយៗ ត្រូវប្រើប្រាស់សម្រាប់គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់អនុវត្តតួនាទី និងភារកិច្ចរបស់ខ្លួននៅឆ្នាំបន្ទាប់ ។

# ៣. ការអនុវត្តមុខងារ

## ៣.១. ការប្រជុំរបស់គណៈកម្មាធិការ

គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ ត្រូវអនុវត្តរបៀបរបបប្រជុំការងាររបស់ខ្លួន ដូចមានចែងក្នុងបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រង់ជំពូក៩ ដែលចែងអំពីគណៈកម្មាធិការជំនួយការរបស់ឃុំ សង្កាត់ ។ ផ្អែកតាមរបៀបរបបប្រជុំការងារ គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ ត្រូវរៀបចំកិច្ចប្រជុំប្រចាំខែ ប្រចាំឆមាស និងប្រចាំឆ្នាំរបស់ខ្លួនឱ្យបានទៀងទាត់ ។ ក្រៅពីការប្រជុំជាទៀងទាត់ គណៈកម្មាធិការក៏អាចរៀបចំប្រជុំវិសាមញ្ញទៅតាមស្ថានភាពជាក់ស្តែងផងដែរ ។

### ៣.១.១. ការប្រជុំប្រចាំខែ

ក). គោលបំណង : គណៈកម្មាធិការត្រូវរៀបចំប្រជុំប្រចាំខែរបស់ខ្លួន ដើម្បីពិនិត្យអំពីភាពរីកចម្រើន និងដោះស្រាយបញ្ហានានាពាក់ព័ន្ធនឹងនារី និងកុមារនៅក្នុងឃុំ សង្កាត់ ។

ខ). អ្នកចូលរួម : សមាជិកគណៈកម្មាធិការដែលត្រូវអញ្ជើញចូលរួមប្រជុំប្រចាំខែរួមមាន ÷

- ប្រធានគណៈកម្មាធិការ
- អនុប្រធាន គណៈកម្មាធិការ
- សមាជិកអចិន្ត្រៃយ៍គណៈកម្មាធិការ

- ស្មៀនឃុំ សង្កាត់
- នាយ ឬនាយរងប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់១រូប
- នាយកសាលា ឬតំណាង១រូបមកពីគ្រប់សាលាក្នុងឃុំ សង្កាត់ និង
- ប្រធានមណ្ឌលសុខភាព ឬតំណាង១រូបមកពីគ្រប់មណ្ឌលសុខភាព ដែលពាក់ព័ន្ធ។

បើអាចធ្វើបាន ប្រធានគណៈកម្មាធិការអាចអញ្ជើញមេភូមិ ឬអនុប្រធានភូមិដែលជាសមាជិកគណៈកម្មាធិការពីគ្រប់ភូមិ ដើម្បីចូលរួមប្រជុំប្រចាំខែ។

គ). **ប្រធានអង្គប្រជុំ :** ប្រធាន ឬប្រធានស្តីទីរបស់គណៈកម្មាធិការ។

ឃ). **អ្នកកត់ត្រា :** ស្មៀនឃុំ សង្កាត់ ឬអ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់។

ង). **រយៈពេល :** មួយព្រឹក ឬមួយល្ងាច (កន្លះថ្ងៃ)

ច). **របៀបវារៈ :** រាល់ការប្រជុំប្រចាំខែរបស់គណៈកម្មាធិការត្រូវផ្តោតលើរបៀបវារៈមួយចំនួនដូចខាងក្រោម ÷

- ពិនិត្យលើរបាយការណ៍ប្រជុំខែមុន
- រាយការណ៍ និងពិភាក្សាអំពីផ្នែកសេវាសុខភាព
- រាយការណ៍ និងពិភាក្សាអំពីផ្នែកអប់រំ
- រាយការណ៍ និងពិភាក្សាអំពីការចុះបញ្ជីកំណើតនៅក្នុងឃុំ សង្កាត់
- រាយការណ៍ និងពិភាក្សាអំពីបញ្ហាចម្បងៗពាក់ព័ន្ធនារី និងកុមារនៅក្នុងឃុំ សង្កាត់

- រាយការណ៍ និងពិភាក្សាអំពីបញ្ហាសន្តិសុខ និងសណ្តាប់ធ្នាប់នៅក្នុងឃុំ សង្កាត់
- រាយការណ៍អំពីការប្រើប្រាស់ថវិការបស់គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់
- ផ្សេងៗ។

ឃ). **ដំណើរការប្រជុំ :** ការប្រជុំរបស់គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ អាចប្រព្រឹត្តតាមសកម្មភាពដូចខាងក្រោម ÷

- មេឃុំ ចៅសង្កាត់ដែលជាប្រធានគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ ÷
  - មានមតិបើកកិច្ចប្រជុំប្រចាំខែ
  - អានអំពីបញ្ហា ឬផែនការសកម្មភាពដែលឯកភាពកាលពីប្រជុំលើកមុន និងពិនិត្យមើលអំពីភាពរីកចម្រើន
  - បញ្ជាក់អំពីបញ្ហាដែលមិនទាន់បានដោះស្រាយ និងឯកភាពលើផែនការសកម្មភាពបន្ត។
- ប្រធាន ឬតំណាងមណ្ឌលសុខភាពនៅក្នុងឃុំ សង្កាត់ និងមណ្ឌលសុខភាពពាក់ព័ន្ធ ដែលជាសមាជិកគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ រាយការណ៍អំពីព័ត៌មានខាងក្រោមនេះ ដោយផ្អែកតាមរបាយការណ៍មណ្ឌលសុខភាពប្រចាំខែ ÷
  - ចំនួនស្ត្រីមានផ្ទៃពោះសរុបនៅក្នុងឃុំ សង្កាត់

- ចំនួនស្ត្រីមានផ្ទៃពោះបានទទួលការពិនិត្យផ្ទៃពោះ
- ចំនួនស្ត្រីមានផ្ទៃពោះសម្រាលកូនសរុបនៅក្នុងឃុំ សង្កាត់
- ចំនួនស្ត្រីមានផ្ទៃពោះបានសម្រាលកូនដោយឆ្មបជំនាញនៅកន្លែងផ្តល់សេវាសុខាភិបាល( មណ្ឌលសុខភាព សម្ភព មន្ទីរ ពេទ្យ)
- ចំនួនស្ត្រីមានផ្ទៃពោះសម្រាលកូនដោយឆ្មបជំនាញនៅតាមផ្ទះ
- ចំនួនស្ត្រីមានផ្ទៃពោះសម្រាលកូនដោយឆ្មបបុរាណនៅតាមផ្ទះ
- ចំនួនស្ត្រីមានផ្ទៃពោះស្លាប់ពេលមានផ្ទៃពោះ ពេលសម្រាល និងក្រោយសម្រាល
- ចំនួនកុមារអាយុក្រោម១ឆ្នាំសរុបនៅក្នុងឃុំ សង្កាត់
- ចំនួនកុមារអាយុក្រោម១ឆ្នាំទទួលបានការចាក់ថ្នាំបង្ការជំងឺកញ្ជ្រិល
- ចំនួនកុមារអាយុក្រោម៥ឆ្នាំសរុបនៅក្នុងឃុំ សង្កាត់
- ចំនួនកុមារអាយុក្រោម៥ឆ្នាំទទួលមរណៈភាពក្នុងអំឡុងខែមុន

• នាយកសាលា ឬតំណាងនាយកសាលាទាំងអស់នៅក្នុងឃុំ សង្កាត់ដែលជាសមាជិកគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ រាយការណ៍អំពីព័ត៌មានខាងក្រោមនេះ ដោយផ្អែកតាមរបាយការណ៍សាលារៀនប្រចាំខែ ÷

  - ចំនួនកុមារអាយុ៦-១១ឆ្នាំសរុបនៅក្នុងឃុំ សង្កាត់
  - ចំនួនកុមារអាយុ៦-១១ឆ្នាំដែលបានចុះឈ្មោះចូលរៀននៅសាលាបឋមសិក្សា

- ចំនួនកុមារអាយុ៦-១១ឆ្នាំអវត្តមានពីសាលារៀនលើសពី ១៥ថ្ងៃជាប់ៗគ្នា
- ភាគរយកុមារអាយុ៦-១១ឆ្នាំអវត្តមានពីសាលារៀនលើស ពី១៥ថ្ងៃជាប់ៗគ្នា

- ស្មៀនឃុំ សង្កាត់ រាយការណ៍អំពីព័ត៌មានខាងក្រោមនេះ ដោយផ្អែកតាមរបាយការណ៍ប្រចាំខែស្តីពីការចុះអត្រានុកូលដ្ឋានកំណើត និងការអនុវត្តថវិការបស់គណៈកម្មាធិការ ÷
  - ចំនួនទារកកើតនៅក្នុងឃុំ សង្កាត់សរុប( គិតក្នុងខែ)
  - ចំនួនទារកដែលបានចុះបញ្ជីកំណើត ( គិតក្នុងខែ)
  - ភាគរយចំនួនទារកដែលបានចុះបញ្ជីកំណើត ( គិតក្នុងខែ)
  - ការប្រើប្រាស់មូលនិធិរបស់គ.ក.ន.ក
- អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់រាយការណ៍ព័ត៌មានអំពីព្រឹត្តិការណ៍ ឬសកម្មភាពចម្បងៗពាក់ព័ន្ធនារីនិងកុមារ នៅក្នុងឃុំសង្កាត់ដូចជា ការផ្សព្វផ្សាយ ការបណ្តុះបណ្តាល ការរៀបចំវេទិការ ការសិក្សាវាយតម្លៃជាដើម ដែលធ្វើឡើងនៅក្នុងឃុំសង្កាត់ ។
- នាយនគរបាលប៉ុស្តិ៍ ឬតំណាងដែលជាសមាជិកគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ រាយការណ៍ដោយផ្អែកតាមរបាយការណ៍ប្រចាំខែស្តីពីបញ្ហាសន្តិសុខ និងសណ្តាប់ធ្នាប់នៅក្នុងឃុំសង្កាត់ ។ ព័ត៌មានដែលត្រូវរាយការណ៍អាចមានដូចជា ÷

- ករណីចោរកម្ម
- សកម្មភាពក្រុមក្មេងពាល
- អំពើហិង្សា
- គ្រោះថ្នាក់ចរាចរ
- ល្បែងស៊ីសង
- ការឆបោក ... ។ល។

- បន្ទាប់ពីផ្នែកពាក់ព័ន្ធនីមួយៗបានរាយការណ៍ និងពិភាក្សាចប់សព្វគ្រប់ ប្រធានអង្គប្រជុំត្រូវផ្តល់ឱកាសឱ្យអ្នកចូលរួមទាំងអស់លើកឡើងអំពីបញ្ហាផ្សេងៗ និងបូកសរុបលទ្ធផលនៃកិច្ចប្រជុំ និងបញ្ជាក់ឡើងវិញអំពីសកម្មភាពដែលត្រូវអនុវត្តបន្ត។

| |
|---|
| កំណត់សម្គាល់ : បន្ទាប់ពីផ្នែកនីមួយៗរាយការណ៍ចប់ ប្រធានអង្គប្រជុំ ត្រូវដឹកនាំការពិភាក្សាដើម្បីកំណត់នូវដំណោះស្រាយ និងរៀបចំផែនការសកម្មភាពសម្រាប់អនុវត្តនូវដំណោះស្រាយដែលបានកំណត់។ |

### ៣.១.២. ការប្រជុំប្រចាំឆមាស និងប្រចាំឆ្នាំ

ក). **គោលបំណង :** គោលបំណងនៃកិច្ចប្រជុំប្រចាំឆ្នាំ ឬប្រចាំឆមាសត្រូវបានធ្វើឡើងដើម្បីពិនិត្យឡើងវិញអំពី ÷

- ការអនុវត្តមុខងារ និងភារកិច្ចរបស់សមាជិកគណៈកម្មាធិការ
- កម្រិតការឆ្លើយតបទៅនឹងសូចនាករនៃការផ្តល់មូលនិធិគាំទ្រ
- ការប្រើប្រាស់មូលនិធិគាំទ្រ។

ខ). **អ្នកចូលរួម :** សមាជិកគណៈកម្មាធិការទាំងអស់ត្រូវចូលរួមប្រជុំប្រចាំឆមាស និងប្រចាំឆ្នាំរបស់គណៈកម្មាធិការ។

គ). **ប្រធានអង្គប្រជុំ :** ប្រធាន ឬប្រធានស្តីទីរបស់គណៈកម្មាធិការ ។

ឃ). **អ្នកកត់ត្រា :** ស្មៀនឃុំ សង្កាត់ ឬអ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ ។

ង). **រយៈពេល :** មួយព្រឹក ឬមួយល្ងាច ( កន្លះថ្ងៃ )

ច). **របៀបវារៈ :** ការប្រជុំប្រចាំឆមាស និងប្រចាំឆ្នាំរបស់គណៈកម្មាធិការត្រូវផ្តោតលើរបៀបវារៈមួយចំនួនដូចខាងក្រោម ÷

- បូកសរុបលទ្ធផលនៃការអនុវត្ត ដោយធៀបជាមួយសូចនាករដែលបានកំណត់
- កំណត់នូវដំណោះស្រាយសមស្រប និងរៀបចំផែនការសកម្មភាព
- ការអនុវត្តថវិកាគាំទ្រគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ ។

### ៣.១.៣. ការប្រជុំវិសាមញ្ញ

គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់អាចរៀបចំប្រជុំវិសាមញ្ញ នៅពេលណាក៏បាន តាមការកោះអញ្ជើញរបស់ប្រធានគណៈកម្មាធិការ ។ ចំពោះសមាជិកដែលត្រូវអញ្ជើញចូលរួមប្រជុំអាស្រ័យទៅលើការសម្រេចរបស់ប្រធាន ។

## ៣.២. ទម្រង់របាយការណ៍ និងកំណត់ហេតុ

### ៣.២.១. របាយការណ៍អំពីផ្នែកសុខភាព

ប្រធាន ឬតំណាងមណ្ឌលសុខភាពត្រូវសហការជាមួយមេភូមិ អ្នកស្ម័គ្រចិត្តសុខភាពភូមិ និងអ្នកពាក់ព័ន្ធដទៃទៀត ដើម្បីជំរុញឱ្យ ÷

- ស្ត្រីមានផ្ទៃពោះទទួលសេវាពិនិត្យផ្ទៃពោះ
- ស្ត្រីមានផ្ទៃពោះសម្រាលកូនដោយពេទ្យឆ្មបនៅកន្លែងផ្តល់សេវាសុខាភិបាល( មណ្ឌលសុខភាព ឬមន្ទីរពេទ្យ ឬសម្ភព)
- ទារក និងកុមារអាយុក្រោម១ឆ្នាំបានទទួលថ្នាំបង្ការជំងឺប្រាំពីរមុខគ្រប់ៗគ្នា

ប្រធាន ឬតំណាងមណ្ឌលសុខភាព ត្រូវប្រើប្រាស់ទម្រង់របាយការណ៍អំពីផ្នែកសុខភាពខាងក្រោមនេះ ។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ខេត្ត ក្រុង :..........................
ស្រុក ខណ្ឌ :..........................
ឃុំ សង្កាត់ :..........................

**របាយការណ៍មណ្ឌលសុខភាព......................**

**សម្រាប់ខែ.............. ឆ្នាំ.................**

| ល.រ | ការបរិយាយ | ចំនួន | ភាគរយ |
|---|---|---|---|
| ១ | ស្ត្រីមានផ្ទៃពោះសរុប ( គិតត្រឹមខែនេះ) | | |
| ២ | ស្ត្រីមានផ្ទៃពោះបានទទួលការពិនិត្យផ្ទៃពោះ | | |

| ល.រ | ការបរិយាយ | ចំនួន | ភាគរយ |
|---|---|---|---|
| ៣ | ស្ត្រីមានផ្ទៃពោះសម្រាលកូនសរុប | | |
| ៤ | ស្ត្រីមានផ្ទៃពោះបានសម្រាលកូនដោយឆ្មបជំនាញនៅកន្លែងផ្តល់សេវាសុខាភិបាល ( មណ្ឌល សុខភាព សម្ភព មន្ទីរពេទ្យ) | | |
| ៥ | ស្ត្រីមានផ្ទៃពោះសម្រាលកូនដោយឆ្មបជំនាញ នៅតាមផ្ទះ | | |
| ៦ | ស្ត្រីមានផ្ទៃពោះសម្រាលកូនដោយឆ្មបបុរាណ នៅតាមផ្ទះ | | |
| ៧ | ស្ត្រីមានផ្ទៃពោះស្លាប់ពេលមានផ្ទៃពោះ ពេលសម្រាល និង ក្រោយសម្រាល | | |
| ៨ | កុមារអាយុក្រោម១ឆ្នាំសរុប | | |
| ៩ | កុមារអាយុក្រោម១ឆ្នាំទទួលបានការចាក់ថ្នាំ បង្ការជំងឺកញ្ជ្រិល | | |
| ១០ | កុមារអាយុក្រោម៥ឆ្នាំសរុប | | |
| ១១ | កុមារអាយុក្រោម៥ឆ្នាំទទួលមរណៈភាពក្នុងអំឡុងខែមុន | | |

ធ្វើនៅ................ ថ្ងៃទី......... ខែ........... ឆ្នាំ..........

ហត្ថលេខា

## ៣.២.២. របាយការណ៍អំពីផ្នែកអប់រំ

តាមរយៈការធ្វើជំរឿនកុមារក្នុងឃុំ សង្កាត់ និងតាមរយៈការសហការជាមួយមេភូមិ គណៈកម្មការមាតាបិតាសិស្ស និងអ្នកពាក់ព័ន្ធដទៃទៀត នាយកសាលា ឬតំណាងសាលាពាក់ព័ន្ធដែលជាសមាជិកគណៈកម្មាធិការ ត្រូវជំរុញឱ្យកុមារគ្រប់អាយុចុះឈ្មោះចូលរៀន និងមករៀនឱ្យបានទៀតទាត់គ្រប់ៗគ្នា ហើយត្រូវរាយការណ៍អំពីផ្នែកអប់រំតាមទម្រង់របាយការណ៍ខាងក្រោមនេះ ។

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

ខេត្ត ក្រុង :.........................

ស្រុក ខណ្ឌ :.........................

ឃុំ សង្កាត់ :.........................

**របាយការណ៍សាលា.......................**

**សម្រាប់ខែ.......... ឆ្នាំ............**

| ល.រ | ការបរិយាយ | ចំនួនកុមារ | | |
|---|---|---|---|---|
| | | កុមារា | កុមារី | សរុប |
| ១ | កុមារអាយុ៦-១១សរុប | | | |
| ២ | កុមារអាយុ៦-១១ឆ្នាំបានចុះឈ្មោះចូលរៀននៅសាលាបឋមសិក្សា | | | |
| ៣ | កុមារអាយុ៦-១១ឆ្នាំអវត្តមានពីសាលារៀនលើសពី១៥ថ្ងៃជាប់ៗគ្នា | | | |
| ៤ | ភាគរយកុមារអាយុ៦-១១ឆ្នាំអវត្តមានពីសាលារៀនលើសពី១៥ថ្ងៃជាប់ៗគ្នា | | | |

ធ្វើនៅ................ ថ្ងៃទី......... ខែ............ ឆ្នាំ..........

**ហត្ថលេខា**

## ៣.២.៣. របាយការណ៍អំពីការចុះសំបុត្រកំណើត

ស្មៀនឃុំ សង្កាត់ ដោយមានការសហការជាមួយមេភូមិ ត្រូវជំរុញឱ្យឪពុកម្តាយរបស់ទារក និងកុមារដែលមិនទាន់បានចុះសំបុត្រកំណើតនាំកូនមកចុះសំបុត្រកំណើតឱ្យបានគ្រប់ៗគ្នា ហើយត្រូវរាយការណ៍អំពីការចុះសំបុត្រកំណើតដោយប្រើទម្រង់របាយការណ៍ខាងក្រោមនេះ។

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

ខេត្ត ក្រុង :..........................

ស្រុក ខណ្ឌ :..........................

ឃុំ សង្កាត់ :..........................

**របាយការណ៍អំពីការចុះសំបុត្រកំណើត**

**សម្រាប់ខែ............ ឆ្នាំ..............**

| ល.រ | ការបរិយាយ | ប្រុស | ស្រី | សរុប |
|---|---|---|---|---|
| ១ | ចំនួនទារកកើតក្នុងឃុំ សង្កាត់ ( គិតក្នុងខែនេះ) | | | |
| ២ | ចំនួនទារកដែលបានចុះបញ្ជីកំណើត( គិតក្នុងខែនេះ) | | | |
| ៣ | ភាគរយទារកដែលបានចុះបញ្ជីកំណើត( គិតក្នុងខែនេះ) | | | |

ធ្វើនៅ................ ថ្ងៃទី........ ខែ............. ឆ្នាំ..........

**ហត្ថលេខា**

## ៣.២.៤. របាយការណ៍ស្តីពីសកម្មភាពពាក់ព័ន្ធនារីនិងកុមារនៅក្នុង ឃុំ សង្កាត់

អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ ត្រូវសហការជាមួយមេឃុំចៅសង្កាត់ ស្មៀនឃុំសង្កាត់ មេភូមិ និងអ្នកពាក់ព័ន្ធផ្សេងៗទៀត ដើម្បីចូលរួម និងរាយការណ៍អំពីព្រឹត្តិការណ៍ ឬសកម្មភាពដែលពាក់ព័ន្ធនឹងស្ត្រី និងកុមារក្នុងឃុំ សង្កាត់ ព្រមទាំងលើកឡើងនូវបញ្ហាប្រឈមនានា ដោយប្រើទម្រង់របាយការណ៍ដូចខាងក្រោម ។

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

ខេត្ត ក្រុង :.........................

ស្រុក ខណ្ឌ :.........................

ឃុំ សង្កាត់ :.........................

**របាយការណ៍ស្តីពី**

**សកម្មភាពពាក់ព័ន្ធនារី និងកុមារនៅក្នុងឃុំ សង្កាត់**

**សម្រាប់ខែ............ ឆ្នាំ..............**

| ល.រ | ព្រឹត្តិការណ៍ ឬសកម្មភាព | ទីតាំង | ពេលវេលា | បញ្ហាប្រឈម |
|---|---|---|---|---|
| ១ | | | | |
| ២ | | | | |
| ៣ | | | | |
| ..... | | | | |

ធ្វើនៅ............... ថ្ងៃទី........ ខែ............ ឆ្នាំ.........

**ហត្ថលេខា**

## ៣.២.៥. របាយការណ៍ស្តីពីសន្តិសុខ និងសណ្តាប់ធ្នាប់

នាយនគរបាលប៉ុស្តិ៍រដ្ឋបាលឃុំ សង្កាត់ ឬតំណាងដែលជាសមាជិកគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ ត្រូវសហការជាមួយមេឃុំ ចៅសង្កាត់ អ្នកទទួលបន្ទុកកិច្ចការនារីនិងកុមារឃុំសង្កាត់ មេភូមិ និងអ្នកពាក់ព័ន្ធផ្សេងទៀត ដើម្បីជំរុញ និងធានាឱ្យមាននូវសុវត្ថិភាព សន្តិសុខ និងសណ្តាប់ធ្នាប់នៅក្នុងឃុំ សង្កាត់ ហើយត្រូវរាយការណ៍អំពីញ្ហាសន្តិសុខ និងសណ្តាប់ធ្នាប់នៅក្នុងឃុំ សង្កាត់ ដោយប្រើទម្រង់របាយការណ៍ខាងក្រោម ។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ខេត្ត ក្រុង :..........................
ស្រុក ខណ្ឌ :..........................
ឃុំ សង្កាត់ :..........................

**របាយការណ៍អំពីបញ្ហាសន្តិសុខ និងសណ្តាប់ធ្នាប់**

**សម្រាប់ខែ............ ឆ្នាំ..............**

| ល.រ | បញ្ហា | ការបរិយាយ | ផ្សេងៗ |
|---|---|---|---|
| | | | |
| | | | |
| | | | |
| | | | |

ធ្វើនៅ............... ថ្ងៃទី........ ខែ........... ឆ្នាំ..........

**ហត្ថលេខា**

## ៣.២.៦. របាយការណ៍អំពីការប្រើប្រាស់ថវិកាគណៈកម្មាធិការ

ស្មៀនឃុំ សង្កាត់ដែលជាលេខាធិការឃុំ សង្កាត់ត្រូវរាយការណ៍អំពីការប្រើប្រាស់ថវិការបស់គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារីឃុំសង្កាត់ ដោយប្រើទម្រង់របាយការណ៍ខាងក្រោម ។

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ខេត្ត ក្រុង :........................

ស្រុក ខណ្ឌ :........................

ឃុំ សង្កាត់ :........................

## របាយការណ៍អំពីការប្រើប្រាស់ថវិកា គ.ក.ន.ក

## សម្រាប់ខែ............ ឆ្នាំ............

| ល.រ | ការបរិយាយ | ថវិកាសរុប | ការចំណាយ | | | សមតុល្យ |
|---|---|---|---|---|---|---|
| | | | កន្លងមក | ក្នុងខែ | បូកយោង | |
| ១ | ការរៀបចំកិច្ចប្រជុំ | | | | | |
| ២ | សម្ភារៈការិយាល័យ | | | | | |
| ៣ | ថ្លៃធ្វើដំណើរ | | | | | |
| សរុប | | | | | | |

ធ្វើនៅ................ ថ្ងៃទី........ ខែ............ ឆ្នាំ.........

**ហត្ថលេខា**

## ៣.២.៧. កំណត់ហេតុប្រជុំរបស់គណៈកម្មាធិការ

ស្មៀនឃុំ សង្កាត់ ឬអ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ ត្រូវរៀបចំកំណត់ប្រជុំប្រចាំខែ ឆមាស និងប្រចាំឆ្នាំរបស់គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ ដោយប្រើទម្រង់កំណត់ហេតុប្រជុំដូចខាងក្រោម ។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ខេត្ត ក្រុង :..........................
ស្រុក ខណ្ឌ :..........................
ឃុំ សង្កាត់ :..........................

## កំណត់ហេតុប្រជុំ
## របស់គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់
## សម្រាប់ខែ.......... ឆ្នាំ............

ឆ្នាំ........ ខែ........ ថ្ងៃទី....... វេលាម៉ោង........ ( ថ្ងៃខែឆ្នាំត្រូវសរសេរជាអក្សរ) នៅ..................... បានរៀបចំកិច្ចប្រជុំប្រចាំខែ........ របស់គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំសង្កាត់ ក្រោមអធិបតីភាពលោក លោកស្រី.................................. ជាប្រធាន គ.ក.ន.ក ។

### I. សមាសភាពអ្នកចូលរួម

សមាជិក សមាជិកានៃ គ.ក.ន.ក បានចូលរួមប្រជុំមានចំនួន.........រូប ក្នុង នោះស្ត្រី........រូប នៃសមាជិក គ.ក.ន.ក សរុបចំនួន.........រូប ។

### II. របៀបវារៈ

របៀបវារៈនៃការប្រជុំមានដូចខាងក្រោម ÷

១. ពិនិត្យលើរបាយការណ៍ប្រជុំខែមុន

២. រាយការណ៍ និងពិភាក្សាអំពីផ្នែកសេវាសុខភាព

៣. រាយការណ៍ និងពិភាក្សាអំពីផ្នែកអប់រំ

៤. រាយការណ៍ និងពិភាក្សាអំពីការចុះបញ្ជីកំណើតនៅក្នុងឃុំ សង្កាត់

៥. រាយការណ៍ និងពិភាក្សាអំពីបញ្ហាចម្រូងចម្រាសនានាទាក់ទងនឹងនារី និងកុមារនៅក្នុងឃុំ សង្កាត់

៦. រាយការណ៍ និងពិភាក្សាអំពីបញ្ហាសន្តិសុខ និងសណ្តាប់ធ្នាប់នៅក្នុងឃុំ សង្កាត់

៧. រាយការណ៍អំពីការប្រើប្រាស់ថវិការបស់គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់

៨. ផ្សេងៗ។

## III. លទ្ធផល

១). ពិនិត្យលើរបាយការណ៍ប្រជុំខែកន្លងមក

២). អំពីផ្នែកសេវាសុខភាព

សកម្មភាពដែលត្រូវអនុវត្តបន្ត :

- ...............................................................................................
- ...............................................................................................

៣). អំពីផ្នែកអប់រំ

សកម្មភាពដែលត្រូវអនុវត្តបន្ត :

- ...............................................................................................
- ...............................................................................................

៤). ការចុះបញ្ជីកំណើតកុមារនៅក្នុងឃុំ សង្កាត់

សកម្មភាពដែលត្រូវអនុវត្តបន្ត :

- ...............................................................................................
- ...............................................................................................

៥). ព្រឹត្តិការណ៍ ឬសកម្មភាពពាក់ព័ន្ធ នារីនិងកុមារ នៅក្នុងឃុំ សង្កាត់

សកម្មភាពដែលត្រូវអនុវត្តបន្ត :

- ..........................................................................................
- ..........................................................................................

៦). បញ្ហាសន្តិសុខ និងសណ្តាប់ធ្នាប់នៅក្នុងឃុំ សង្កាត់

សកម្មភាពដែលត្រូវអនុវត្តបន្ត :

- ..........................................................................................
- ..........................................................................................

៧). ការប្រើប្រាស់ថវិកា គ.ក.ន.ក

៨). ផ្សេងៗ

ថ្ងៃទី.......... ខែ.......... ឆ្នាំ.......... **អ្នកធ្វើកំណត់ហេតុ**

**ប្រធានអង្គប្រជុំ**

| |
|---|
| បញ្ជាក់ : របាយការណ៍តាមផ្នែកនីមួយៗ ត្រូវភ្ជាប់ជាមួយកំណត់ហេតុប្រជុំរបស់គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ ។ |

## ៣.២.៨. របាយការណ៍រីកចម្រើនរបស់គណៈកម្មាធិការ

ស្មៀនឃុំ សង្កាត់ ឬអ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ត្រូវរៀបចំរបាយការណ៍រីកចម្រើនរៀងរាល់បីខែម្តង (មករា-មីនា មេសា-មិថុនា កក្កដា-កញ្ញា និងតុលា-ធ្នូ) របស់គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ ដោយប្រើទម្រង់របាយការណ៍ដូចខាងក្រោម ។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ខេត្ត ក្រុង :..........................
ស្រុក ខណ្ឌ :..........................
ឃុំ សង្កាត់ :..........................

# របាយការណ៍រីកចម្រើន

## របស់គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់

ចាប់ខែ......... ដល់ខែ.......... ឆ្នាំ.......

១. លទ្ធផលនៃការអនុវត្តការងារ

| ល.រ | ការបរិយាយ | %សម្រេចបាន |
|---|---|---|
| ១ | ស្ត្រីមានផ្ទៃពោះបានទទួលការពិនិត្យផ្ទៃពោះ | |
| ២ | ស្ត្រីមានផ្ទៃពោះបានសម្រាលកូនដោយឆ្មបជំនាញនៅកន្លែងផ្តល់សេវាសុខាភិបាល ( មណ្ឌលសុខភាព សម្ភព មន្ទីរពេទ្យ) | |
| ៣ | ស្ត្រីមានផ្ទៃពោះសម្រាលកូនដោយឆ្មបជំនាញនៅតាមផ្ទះ | |
| ៤ | ស្ត្រីមានផ្ទៃពោះសម្រាលកូនដោយឆ្មបបុរាណនៅតាមផ្ទះ | |
| ៥ | ស្ត្រីមានផ្ទៃពោះស្លាប់ពេលមានផ្ទៃពោះ ពេលសម្រាល និងក្រោយសម្រាល | |
| ៦ | កុមារអាយុក្រោម១ឆ្នាំទទួលបានការចាក់ថ្នាំបង្ការជំងឺកញ្ជ្រិល | |
| ៧ | កុមារអាយុក្រោម៥ឆ្នាំទទួលមរណៈភាពក្នុងអំឡុងខែមុន | |
| ៨ | ទារកទើបកើតបានទទួលសំបុត្រកំណើតក្នុងរយៈពេល៣០ថ្ងៃ | |
| ៩ | កុមារអាយុ៦-១១ឆ្នាំបានចុះឈ្មោះចូលរៀននៅសាលាបឋមសិក្សា | |

| ល.រ | ការបរិយាយ | %សម្រេចបាន |
|---|---|---|
| ១០ | កុមារអាយុ៦-១១ឆ្នាំអវត្តមានពីសាលារៀនលើសពី១៥ថ្ងៃជាប់ៗគ្នា | |

២. លទ្ធផលនៃការអនុវត្តថវិការបស់គណៈកម្មាធិការ

| ល.រ | ការបរិយាយ | ថវិកាសរុប | ចំណាយសរុប | សមតុល្យ |
|---|---|---|---|---|
| ១ | ការរៀបចំកិច្ចប្រជុំ | | | |
| ២ | សម្ភារៈការិយាល័យ | | | |
| ៣ | ថ្លៃធ្វើដំណើរ | | | |
| សរុប | | | | |

៣. បញ្ហាផ្សេងៗ

.............................................................................................................

.............................................................................................................

ថ្ងៃទី.......... ខែ.......... ឆ្នាំ..........

ថ្ងៃទី.......... ខែ.......... ឆ្នាំ..........

**អ្នកធ្វើរបាយការណ៍**

**មេឃុំ ចៅសង្កាត់**

# ៤. យន្តការគាំទ្រ

## ៤.១. អង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត ក្រុង

អង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត ក្រុងដែលមានតួនាទីជាជំនួយការឱ្យអភិបាលខេត្ត ក្រុងក្នុងការអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងគោលនយោបាយវិមជ្ឈការនៅក្នុងខេត្ត ក្រុងរបស់ខ្លួន មានតួនាទី និងភារកិច្ចគាំទ្រគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ដូចខាងក្រោម ÷

- សម្របសម្រួល និងសហការជាមួយមន្ទីរកិច្ចការនារីខេត្ត ក្រុង មន្ទីរ អង្គភាព និងភ្នាក់ងារពាក់ព័ន្ធនានា ដើម្បីអប់រំបណ្តុះបណ្តាល និងកសាងសមត្ថភាពដល់គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់។
- ទំនាក់ទំនង និងសហការជាមួយមន្ទីរអប់រំ យុវជន និងកីឡា មន្ទីរសុខាភិបាល មន្ទីរអភិវឌ្ឍន៍ជនបទ មន្ទីរកិច្ចការនារី មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ស្នងការដ្ឋាននគរបាលខេត្ត ក្រុង និងមន្ទីរវិស័យនានាក្នុងខេត្ត ក្រុងពាក់ព័ន្ធបញ្ហា និងតម្រូវការរបស់នារី និងកុមារ។
- ពង្រឹងទំនាក់ទំនងរវាងគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ ជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ និងជាមួយអ្នកផ្តល់សេវាសង្គមនានា និងសហគមន៍។

- ផ្សព្វផ្សាយអំពីច្បាប់ គោលនយោបាយនានារបស់រដ្ឋពាក់ព័ន្ធនារី និងកុមារដល់ក្រុមប្រឹក្សាឃុំ សង្កាត់ គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំសង្កាត់ និងអ្នកសម្របសម្រួលខេត្តក្រុង ស្រុកខណ្ឌ ។
- ធានាថា អ្នកសម្របសម្រួលខេត្តក្រុង ស្រុកខណ្ឌ ចូលរួមគាំទ្រ និងផ្តល់យោបល់ដល់ក្រុមប្រឹក្សាឃុំ សង្កាត់ និងគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ ដើម្បីលើកកម្ពស់ស្ថានភាពសុខភាព អប់រំ កិច្ចការពារ និងការអភិវឌ្ឍកុមារតូចៗ។
- ធានាថា ក្រុមប្រឹក្សាឃុំ សង្កាត់ដាក់បញ្ចូលបញ្ហានារី និងកុមារទៅក្នុងរបៀបវារៈនៃកិច្ចប្រជុំ និងបញ្ចូលក្នុងរបាយការណ៍របស់ខ្លួន។
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃនូវការអនុវត្តការងាររបស់គណៈកម្មាធិការ ។
- បូកសរុប និងរៀបចំរបាយការណ៍ដែលទាក់ទងនឹងឃុំសង្កាត់ ដោយមានបញ្ជាក់ច្បាស់លាស់អំពីស្ថានភាពនារី និងកុមារឱ្យបានទៀងទាត់តាមការកំណត់ ។

## ៤.២. មន្ទីរជំនាញនានាក្នុងខេត្ត ក្រុង

### ៤.២.១. មន្ទីរកិច្ចការនារី

មន្ទីរកិច្ចការនារីខេត្ត ក្រុងនឹងចូលរួមជួយកសាងសមត្ថភាពអ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់អំពីទស្សនទានយេនឌ័រ ការបញ្ជ្រាបយេនឌ័រ និងការជំរុញឱ្យមានសមភាពយេនឌ័រនៅក្នុងឃុំ សង្កាត់។

### ៤.២.២. មន្ទីរអប់រំ យុវជន និងកីឡា

មន្ទីរអប់រំ យុវជន និងកីឡាខេត្ត ក្រុងនឹងជួយផ្តល់ការគាំទ្រផ្នែកបច្ចេកទេសដល់នាយកសាលា ឬតំណាងសាលាដែលជាសមាជិកគណៈកម្មាធិការទទួលកិច្ចការនារី និងកុមារឃុំសង្កាត់ក្នុងការអនុវត្តមុខងារឱ្យមានប្រសិទ្ធភាព។

### ៤.២.៣. មន្ទីរសុខាភិបាល

មន្ទីរសុខាភិបាលខេត្ត ក្រុងនឹងជួយផ្តល់ការគាំទ្រផ្នែកបច្ចេកទេសដល់ប្រធាន ឬតំណាងមណ្ឌលសុខភាពក្នុងឃុំ សង្កាត់ និងមណ្ឌលសុខភាពពាក់ព័ន្ធដែលជាសមាជិកគណៈកម្មាធិការទទួលកិច្ចការនារី និងកុមារឃុំ សង្កាត់ ក្នុងការអនុវត្តមុខងារឱ្យមានប្រសិទ្ធភាព។

### ៤.២.៤. ស្នងការនគរបាលខេត្ត ក្រុង

ស្នងការនគរបាលខេត្ត ក្រុងនឹងជួយផ្តល់ការគាំទ្រផ្នែកបច្ចេកទេសដល់ប្រធាន ឬតំណាងប៉ុស្តិ៍រដ្ឋបាលឃុំ សង្កាត់ ដែលជាសមាជិកគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ក្នុងការអនុវត្តមុខងារឱ្យមានប្រសិទ្ធភាព។

## ៤.៣. សាលាស្រុក ខណ្ឌ

សាលាស្រុក ខណ្ឌមានតួនាទី និងភារកិច្ចគាំទ្រគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ ក្នុងការអនុវត្តតួនាទី និងភារកិច្ចរបស់ខ្លួនឱ្យបានល្អប្រសើរ។ តួនាទី និងភារកិច្ចចម្បងរបស់ស្រុក ខណ្ឌ គឺការសម្របសម្រួលកិច្ចប្រជុំប្រចាំត្រីមាសរបស់គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ ក្នុងស្រុក ខណ្ឌរបស់ខ្លួន។

### ៤.៣.១. ការប្រជុំប្រចាំត្រីមាសនៅថ្នាក់ស្រុក ខណ្ឌ

ក). **គោលបំណង** : កិច្ចប្រជុំប្រចាំត្រីមាសនេះ មានគោលបំណងដើម្បីពិនិត្យមើលអំពីការអនុវត្តតួនាទី និងភារកិច្ចរបស់គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ និងផ្តល់ការគាំទ្រនានា។

ខ). **អ្នកចូលរួម** : អ្នកចូលរួមកិច្ចប្រជុំប្រចាំត្រីមាសនេះ រួមមាន ÷

- អភិបាលស្រុក ខណ្ឌ
- ប្រធាន ឬមន្ត្រីអង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត ក្រុង
- ប្រធាន ឬតំណាងការិយាល័យកិច្ចការនារីស្រុក ខណ្ឌ
- ប្រធានគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំសង្កាត់
- សមាជិកអចិន្ត្រៃយ៍គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់
- ប្រធាន ឬតំណាងការិយាល័យពាក់ព័ន្ធនានានៅក្នុងស្រុក ខណ្ឌ។

គ). **ប្រធានអង្គប្រជុំ** : អភិបាលស្រុក ខណ្ឌ គឺជាប្រធានអង្គប្រជុំប្រចាំត្រីមាសនេះ។

ឃ). **អ្នកកត់ត្រា** : ប្រធានអង្គប្រជុំជ្រើសរើសអ្នកចូលរួមប្រជុំណាម្នាក់ ជាអ្នកកត់ត្រា។

ង). **រយៈពេល** : មួយព្រឹក ឬមួយល្ងាច (កន្លះថ្ងៃ)

ច). **របៀបវារៈ** : ការប្រជុំប្រចាំត្រីមាសនេះ ត្រូវផ្តោតលើរបៀបវារៈមួយចំនួនដូចខាងក្រោម ÷

- ពិនិត្យមើលកំណត់ហេតុប្រជុំលើកមុន

- រាយការណ៍ និងពិភាក្សាលើការអនុវត្តតួនាទី និង ភារកិច្ចរបស់ គ.ក.ន.ក ប្រចាំឃុំ សង្កាត់នីមួយៗ និងបញ្ហាចម្បងៗដែលតម្រូវឱ្យមានការគាំទ្រនិងអន្តរាគមន៍ពីថ្នាក់ស្រុក ខណ្ឌ និងថ្នាក់ខេត្ត ក្រុង
- ផ្សព្វផ្សាយអំពីគោលការណ៍ណែនាំ ឬនីតិវិធីពាក់ព័ន្ធនឹងការអនុវត្តតួនាទី និងភារកិច្ចរបស់ គ.ក.ន.ក ( បើមាន)
- បូកសរុបអំពីចំណុចសំខាន់ៗដែលបានឯកភាព និងរៀបចំផែនការសកម្មភាពសម្រាប់អនុវត្តបន្ត ។
- ផ្សេងៗ

ឍ). ដំណើរការប្រជុំ

- ប្រធានអង្គប្រជុំពិនិត្យកំណត់ហេតុប្រជុំលើកមុនម្តងមួយចំណុចៗ
- ប្រធានគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំសង្កាត់ រាយការណ៍អំពីការរីកចម្រើននៃការអនុវត្តតួនាទី និងភារកិច្ចរបស់គណៈកម្មាធិការរបស់ខ្លួន ។
- ផ្សព្វផ្សាយអំពីគោលការណ៍ណែនាំ ឬនីតិវិធីពាក់ព័ន្ធនឹងការអនុវត្តតួនាទី និងភារកិច្ចរបស់គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ ( បើមាន)
- ប្រធានអង្គប្រជុំដឹកនាំការពិភាក្សា សង្ខេបឡើងវិញនូវចំណុចដែលបានឯកភាពគ្នា និងរៀបចំផែនការសកម្មភាពសម្រាប់អនុវត្តបន្ត ។

## ៤.៣.២. ឧម្រង់កំណត់ហេតុប្រជុំប្រចាំត្រីមាសនៅថ្នាក់ស្រុក ខណ្ឌ

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

ខេត្ត ក្រុង :..........................

ស្រុក ខណ្ឌ :..........................

**កំណត់ហេតុប្រជុំត្រីមាសរបស់គណៈកម្មាធិការ**

**ទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់នៅថ្នាក់ស្រុក ខណ្ឌ**

ត្រីមាសទី----- ឆ្នាំ----------

ឆ្នាំ........ ខែ........ ថ្ងៃទី....... វេលាម៉ោង........ ( ថ្ងៃខែឆ្នាំត្រូវសរសេរជាអក្សរ) នៅ.................... បានរៀបចំកិច្ចប្រជុំប្រចាំត្រីមាសទី........ របស់គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ នៅថ្នាក់ស្រុក ខណ្ឌ ក្រោមអធិបតីភាពលោក លោកស្រី................. ជាអភិបាលស្រុក ខណ្ឌ ។

### I. សមាសភាពអ្នកចូលរួម

អ្នកចូលរួមប្រជុំមានចំនួន......រូប ក្នុងនោះស្ត្រី.....រូប( ភ្ជាប់បញ្ជីវត្តមាន) ។

### II. របៀបវារៈ

របៀបវារៈនៃការប្រជុំមានដូចខាងក្រោម ÷

១. ពិនិត្យកំណត់ហេតុប្រជុំត្រីមាសលើកមុន

២. ផ្សព្វផ្សាយអំពីគោលការណ៍ណែនាំ ឬនីតិវិធីពាក់ព័ន្ធនឹងការអនុវត្តតួនាទី និងភារកិច្ចរបស់គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ ( បើមាន ) ។

៣. របាយការណ៍អំពីការអនុវត្តតួនាទី និងភារកិច្ចរបស់គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំសង្កាត់ ក្នុងឃុំ សង្កាត់នីមួយៗ

៤. ពិភាក្សាទៅលើបញ្ហានានា និងកំណត់ដំណោះស្រាយ

៥. សង្ខេបឡើងវិញនូវចំណុចដែលបានឯកភាពគ្នា និងរៀបចំផែនការសកម្មភាពសម្រាប់អនុវត្តបន្ត។

៦. ផ្សេងៗ

## III. លទ្ធផល

៣.១. លទ្ធផលនៃការអនុវត្តការងារ

| ល.រ | ការបរិយាយ | %សម្រេចបាន |
|---|---|---|
| ១ | ស្ត្រីមានផ្ទៃពោះបានទទួលការពិនិត្យផ្ទៃពោះ | |
| ២ | ស្ត្រីមានផ្ទៃពោះបានសម្រាលកូនដោយឆ្មបជំនាញនៅកន្លែងផ្តល់សេវាសុខាភិបាល (មណ្ឌលសុខភាព សម្ភព មន្ទីរពេទ្យ) | |
| ៣ | ស្ត្រីមានផ្ទៃពោះសម្រាលកូនដោយឆ្មបជំនាញនៅតាមផ្ទះ | |
| ៤ | ស្ត្រីមានផ្ទៃពោះសម្រាលកូនដោយឆ្មបបុរាណនៅតាមផ្ទះ | |
| ៥ | ស្ត្រីមានផ្ទៃពោះស្លាប់ពេលមានផ្ទៃពោះ ពេលសម្រាល និងក្រោយសម្រាល | |
| ៦ | កុមារអាយុក្រោម១ឆ្នាំទទួលបានការចាក់ថ្នាំបង្ការជំងឺកញ្ជ្រិល | |
| ៧ | កុមារអាយុក្រោម៥ឆ្នាំទទួលមរណៈភាពក្នុងអំឡុងខែមុន | |
| ៨ | ទារកទើបកើតបានទទួលសំបុត្រកំណើតក្នុងរយៈពេល៣០ថ្ងៃ | |
| ៩ | កុមារអាយុ៦-១១ឆ្នាំបានចុះឈ្មោះចូលរៀននៅសាលាបឋមសិក្សា | |

| ល.រ | ការបរិយាយ | %សម្រេចបាន |
|---|---|---|
| ១០ | កុមារអាយុ៦-១១ឆ្នាំអវត្តមានពីសាលារៀនលើសពី១៥ថ្ងៃជាប់ៗគ្នា | |

## ៣.២. សកម្មភាពដែលត្រូវអនុវត្តបន្ត

- ..............................................................................................
- ..............................................................................................
- ..............................................................................................
- ..............................................................................................
- ..............................................................................................
- ..............................................................................................

**អ្នកធ្វើកំណត់ហេតុ**

ថ្ងៃទី.......... ខែ.......... ឆ្នាំ..........

**ប្រធានអង្គប្រជុំ**

**បញ្ជាក់ :** របាយការណ៍របស់គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ទាំងអស់ ត្រូវភ្ជាប់ជាមួយកំណត់ហេតុប្រជុំប្រចាំត្រីមាសរបស់គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់នៅថ្នាក់ស្រុក ខណ្ឌ។

### ៤.៣.៣. ថវិកាសម្រាប់រៀបចំការប្រជុំប្រចាំត្រីមាសថ្នាក់ស្រុក ខណ្ឌ

ការចំណាយក្នុងការប្រជុំប្រចាំត្រីមាសរបស់គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់នៅថ្នាក់ស្រុក ខណ្ឌ ត្រូវប្រើប្រាស់ថវិការបស់គណៈកម្មាធិការប្រតិបត្តិនៃគណៈកម្មាធិការអភិវឌ្ឍន៍បទខេត្ត ក្រុង នៅក្នុងផែនការដ្ឋបាលមូលដ្ឋាន។ នៅឆ្នាំ២០០៨ ស្រុក ខណ្ឌនីមួយៗនឹងមានថវិកាចំនួន **៣០០ដុល្លារ** សម្រាប់ចំណាយទៅលើការរៀបចំប្រជុំប្រចាំត្រីមាសរបស់គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់នៅថ្នាក់ស្រុក ខណ្ឌ ដូចជា ÷

- អាហារសម្រន់ (០.៥ដុល្លារ/នាក់/ថ្ងៃ)
- សម្ភារៈសម្រាប់ប្រើប្រាស់ក្នុងកិច្ចប្រជុំ
- ថតចម្លងឯកសារនានា។

**បញ្ជាក់ :** ថ្លៃធ្វើដំណើរ និងប្រាក់បេសកកម្មរបស់អ្នកចូលរួមប្រជុំ គឺជាបន្ទុកផ្ទាល់របស់អង្គភាពសាមី។